លេខ ៤១ ចេញផ្សាយថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែតុលា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.

នាព្រឹកថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែតុលា គ.ស. ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ **ន.ប.ធ.** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្តីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ នៅក្នុងកិច្ចប្រជុំនេះ មានការធ្វើបទបង្ហាញពីគ្រប់នាយកដ្ឋានចំណុះនៃ **ន.ប.ធ.** ដោយបានបង្ហាញអំពីសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត ព្រមទាំងមានការពិភាក្សាយ៉ាងផុសផុលក្នុងកម្រិតមន្ត្រី និងថ្នាក់ដឹកនាំរបស់និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) លើបញ្ហាប្រឈម និងដំណោះស្រាយដែលបានអនុវត្តកន្លងមក និងលើកឡើងនូវវិធីសាស្រ្តដើម្បីត្រៀមខ្លួនក្នុងការអនុវត្តការងារនៅត្រីមាសបន្ទាប់ឱ្យកាន់តែល្អប្រសើរថែមទៀត។



រូបភាព៖ កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ ន.ប.ធ.។

## មាតិកា


- កិច្ចប្រជុំស្តីពី "ការបូកសរុបសមិទ្ធផលការងារប្រចាំត្រីមាសទី៣ ឆ្នាំ២០២៤ និងទិសដៅការងារបន្ត" របស់ ន.ប.ធ. ទំព័រទី១
- កិច្ចប្រជុំស្តីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច" ទំព័រទី២
- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងយុទ្ធសាស្រ្តស្តីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ កម្មសិទ្ធិ និងភាគហ៊ុនរបស់រដ្ឋ ទំព័រទី២
- របាយការណ៍សង្ខេបសមិទ្ធផលក្នុងវិស័យបរធនបាលកិច្ចសម្រាប់រយៈពេល ៩ ខែក្នុងឆ្នាំ២០២៤ ទំព័រទី២
- កម្មវិធី "វេទិកាព័ត៌មានឱកាសអាជីវកម្មលើកទី១២ ឆ្នាំ២០២៤" ទំព័រទី៣
- កិច្ចប្រជុំស្តីពី "សេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កសហរ" ទំព័រទី៣
- វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា" ទំព័រទី៣
- កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៤
- កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកា ៩ខែ ឆ្នាំ២០២៤" ទំព័រទី៤
- កិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន ទំព័រទី៤
- កិច្ចប្រជុំដំបូងរបស់ក្រុមការងារអន្តរក្រសួងស្ថាប័នលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៤
- កម្មវិធី "សន្និសីទស្តីពីការវិនិយោគនៅក្នុងប្រទេសកម្ពុជា CAMBODIAN INVESTMENT FORUM" ទំព័រទី៥
- កិច្ចប្រជុំ "ដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចជាលើកទី២" ទំព័រទី៥
- ពិធីព័ត៌មានផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៤ ទំព័រទី៥
- "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា" លើកទី២ ទំព័រទី៦
- វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្មសមាសភាគទី១" ទំព័រទី៦
- គោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម ជា ចាន់តូ តំណាងរាស្រ្តមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ដែលបានទទួលមរណភាព ទំព័រទី៧
- វេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត" ទំព័រទី៧
- កិច្ចពិភាក្សា និងបទបង្ហាញក្នុងវេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត" ទំព័រទី៧
- សិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ស្តីពីការវិភាគស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២៣ ទំព័រទី៨




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំស្ដីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច"

នារសៀលថ្ងៃអង្គារ ៦កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកិច្ចប្រជុំស្ដីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** នៅទីស្ដីការអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**)។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាល និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ។



**រូបភាព៖** កិច្ចប្រជុំស្ដីពី "ការរៀបចំ និងការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច"។

## កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈកម្មសិទ្ធិ និងភាគហ៊ុនរបស់រដ្ឋ

នាព្រឹកថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែតុលា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ, **លោកស្រី ឈាន សុខារី** ប្រធាន-នាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ កម្មសិទ្ធិ និងភាគហ៊ុនរបស់រដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភា-ចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ដោយមានការចូលរួមពី ឯកឧត្តមលោកជំទាវ លោក លោកស្រីជាតំណាង **កសហរ**, និយ័តករក្រោមឱវាទ **អ.ស.ហ.** និងអង្គភាពពាក់ព័ន្ធផ្សេងទៀត តាមរយៈប្រព័ន្ធវីដេអូ Conference។



**រូបភាព៖** កិច្ចប្រជុំពិភាក្សាលើសេចក្ដីព្រាងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ការគ្រប់គ្រងសហគ្រាសសាធារណៈ កម្មសិទ្ធិ និងភាគហ៊ុនរបស់រដ្ឋ។

## កម្មវិធី "វេទិកាពិព័រណ៍ឱកាសអាជីវកម្មលើកទី១២ ឆ្នាំ២០២៤"

នាថ្ងៃពុធ-ព្រហស្បតិ៍ ៧-៨ កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩-១០ ខែតុលា គ.ស. ២០២៤ ដោយមានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ (**ន.ប.ធ.**), **លោក លឹម ឡៃ** អនុប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោកស្រី ស៊ិន សុមាល័យ** ប្រធានការិយាល័យគ្រប់គ្រងបរធនបាលកិច្ចសាធារណៈ និងពាណិជ្ជកម្ម បានអញ្ជើញចូលរួមកម្មវិធី "វេទិកាពិព័រណ៍ឱកាសអាជីវកម្មលើកទី១២ ឆ្នាំ២០២៤" ដែលបានរៀបចំដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅទីស្នាក់ការកណ្ដាលធនាគារ ADB ប្រទេសហ្វីលីពីន ក្នុងគោលបំណងដើម្បីដកស្រង់បទពិសោធន៍ និងសិក្សាឈ្វេងយល់អំពីក្របខណ្ឌបទប្បញ្ញត្តិ ឧត្តមានុវត្តន៍អន្តរជាតិ និងឪដីថលភាវូបនីយកម្ម/បញ្ញាសប្បនិម្មិតក្នុងការជំរុញការអភិវឌ្ឍវិស័យបរធន-បាលកិច្ចនៅកម្ពុជា។ កម្មវិធីនេះដែលមានការអញ្ជើញចូលរួមជាអធិបតីពី**លោកស្រី Fatima Yasmin** អគ្គនាយករងនៃធនាគារ ADB និងសិក្ខា-កាមដែលជាអ្នកជំនាញជាន់ខ្ពស់ និងតំណាងក្រុមហ៊ុន ស្ថាប័នរដ្ឋ និងអង្គការសង្គមស៊ីវិល ដែលមានអ្នកចូលរួមសរុបប្រហែល ១៤០០ នាក់ពីបណ្ដាប្រទេសជុំវិញពិភពលោក។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




រូបភាព៖ កម្មវិធី "វេទិកាពិព័រណ៍ឱកាសអាជីវកម្មលើកទី១២ ឆ្នាំ២០២៤"។

## កិច្ចប្រជុំស្តីពី "សេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កសហវ"

នាព្រឹកថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ ន.ប.ធ. និងសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំកម្រិតថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពី "សេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន **កសហវ**" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីកសហវ និងជាប្រធានក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ កសហវ** ដោយមានការអញ្ជើញចូលរួមពីបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំស្តីពី "សេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន កសហវ"។

## វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា"

នាព្រឹក ថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានដឹកនាំមន្ត្រីទទួលបន្ទុកនៃ **ន.ប.ធ.** ចូលរួមផ្តល់វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ បុគ្គលិកជំនាញ និងបុគ្គលិកពាក់ព័ន្ធរបស់ធនាគារ សហពាណិជ្ជ ក.អ (UCB) ដែលជាធនាគារទទួលបានអាជ្ញាបណ្ណពីនិយ័តករបរធនបាលកិច្ចធ្វើជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬរក្សាទុកក្នុងវិស័យបរធនបាលកិច្ច នៅទីស្នាក់ការកណ្តាលរបស់ធនាគារ សហពាណិជ្ជ ក.អ នៅរាជធានីភ្នំពេញ។




រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ច (សេវារក្សាសុវត្ថិភាព ឬរក្សាទុក) នៅកម្ពុជា"។

## កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) និងជាសមាជិកក្រុមការងារមជ្ឈមណ្ឌលហិរញ្ញវត្ថុ បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិភាក្សាលើរបៀបវារៈសំខាន់ៗ ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច**

**និងហិរញ្ញវត្ថុ** នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយ ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ដែលជាប្រធាន/អនុប្រធាន/សមាជិក/សមាជិកា នៃក្រុមការងារមណ្ឌលហិរញ្ញវត្ថុ។



រូបភាព៖ កិច្ចប្រជុំគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកា ៩ខែ ឆ្នាំ២០២៤"

នារសៀលថ្ងៃពុធ ១៤កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែតុលា គ.ស.២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ អមដោយ **កញ្ញា សុន ចិន្តា** អនុប្រធានការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានចូលរួមកិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកា ៩ខែ ឆ្នាំ២០២៤ របស់អង្គភាព ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម យ៉េត ទីណៃឡល** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាព និងរដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារសុខាភ្នំពេញ។




រូបភាព៖ កិច្ចប្រជុំស្តីពី "ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តថវិកា ៩ខែ ឆ្នាំ២០២៤"។

## កិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារ និងរចនាសម្ព័ន្ធក្រសួងស្ថាប័ន

នារសៀលថ្ងៃព្រហស្បតិ៍ ១៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៧ ខែតុលា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន ផ្សព្វផ្សាយជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, **ឯកឧត្តម ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាព៖ កិច្ចប្រជុំស្តីពីការពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងស្ថាប័ន។

## កិច្ចប្រជុំដំបូងរបស់ក្រុមការងារអន្តរក្រសួងស្ថាប័នលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃសុក្រ ១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែតុលា គ.ស.២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងជាអនុប្រធានក្រុមការងារអន្តរក្រសួងស្ថាប័នលើកកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ (**ក.អ.ប.**) អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងជាសមាជិក **ក.អ.ប.** និង **លោក ហាយ សុវណ្ណា** មន្ត្រីដឹកនាំការងារនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងជាសមាជិក **ក.អ.ប.** បានចូលរួមកិច្ចប្រជុំដំបូងរបស់ **ក.អ.ប.** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ព្រមទាំងជាប្រធានក្រុមការងារ **ក.អ.ប.** ដោយមានការចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធដែលជាសមាជិក **ក.អ.ប.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំជំបូងរបស់ក្រុមការងារអន្តរក្រសួងស្ថាប័នលើកម្ពស់ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុវិស័យហិរញ្ញវត្ថុមិនមែនធនាគារ

## កម្មវិធី “សន្និសីទស្តីពីការវិនិយោគនៅក្នុងប្រទេសកម្ពុជា CAMBODIAN INVESTMENT FORUM”

នាព្រឹកថ្ងៃសៅរ៍ ២រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែតុលា គ.ស. ២០២៤ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច ដោយទទួលបានការ-អនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ(ន.ប.ធ.) បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសនៅក្នុងកម្មវិធី "សន្និសីទស្តីពីការ-វិនិយោគនៅក្នុងប្រទេសកម្ពុជា CAMBODIAN INVESTMENT FORUM" ដោយបានធ្វើបទបង្ហាញក្រោមប្រធានបទស្តីពី "ការវិនិយោគដោយមានទំនុកចិត្ត៖ យន្តការបរធនបាលកិច្ចនៅកម្ពុជា" ព្រមទាំងមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយសវិនិយោគិន និងធុរជនជាច្រើនមកពីវិស័យផ្សេងៗគ្នារួមមានវិស័យធនាគារ វិស័យអចលនវត្ថុ វិស័យបរធនបាលកិច្ច វិស័យសេវាកម្ម វិស័យគណនេយ្យ វិស័យច្បាប់ និងវិស័យធានារ៉ាប់រងជាដើម។




រូបភាព៖ កម្មវិធី "សន្និសីទស្តីពីការវិនិយោគនៅក្នុងប្រទេសកម្ពុជា CAMBODIAN INVESTMENT FORUM"។

## កិច្ចប្រជុំ “ដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច ជាលើកទី២”

ថ្ងៃទី ៦-៧ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣-២៤ ខែតុលា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** បានរៀបចំ និងដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចជាលើកទី២ នៅទីស្តីការនិយ័តករបរធនបាលកិច្ច ដោយមានការអញ្ជើញចូលរួមពីតំណាងក្រុមហ៊ុនបរធនបាល ប្រតិបត្តិករបរធនបាល និងបរធនបាលរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ពី **ន.ប.ធ.**។ សូមបញ្ជាក់ផងដែរថា បន្ទាប់ពីដំណាក់កាលសាកល្បងនេះ ប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ច នឹងត្រូវបានដាក់ឱ្យដំណើរការក្នុងពេលឆាប់ៗខាងមុខ ក្នុងគោលដៅជំរុញ និងសម្រួលដល់ការងារចុះបញ្ជីបរធនបាលកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព។



រូបភាព៖ កិច្ចប្រជុំ "ដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធចុះបញ្ជីបរធនបាលកិច្ចជាលើកទី២"។

## ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា “My First STOCK” ២០២៤

នាព្រឹកថ្ងៃសុក្រ ៨ រោច ខែអស្សុជ ឆ្នាំថោះ ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស. ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៤ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម បណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃផ្សារមូលបត្រកម្ពុជា ដែលធ្វើឡើងនៅផ្សារទំនើបអ៊ីអន១ភ្នំពេញ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ ពិធីពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "My First STOCK" ២០២៤។

## "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា"

នាព្រឹកថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស. ២០២៤ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុង "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ នៅទីស្តីការ **អ.ស.ហ.**។




រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសមាគមអ្នកវាយតម្លៃ និងភ្នាក់ងារអចលនវត្ថុកម្ពុជា។

## វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"

ចាប់ពីថ្ងៃអង្គារ ៥ រោច ដល់ថ្ងៃព្រហស្បតិ៍ ៧ រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២២-២៤ ខែតុលា គ.ស. ២០២៤ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP PIU1, **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវបណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 បានដឹកនាំក្រុមការងារ រៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១" នៅខេត្ត ឧត្តរមានជ័យ ព្រះវិហារ និងខេត្តសៀមរាប។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពមន្ត្រីរបស់ស្ថាប័នហិរញ្ញវត្ថុដៃគូរទាំងពីរ(PFIs) នៃអង្គភាពគ្រប់គ្រងគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម សម្រាប់សមាសភាគទី១ (ACSEP-PIU1) តាមបណ្តាស្រុក និងខេត្តគោលដៅ លើការរៀបចំបំពេញឯកសារពាក់ព័ន្ធ និងប្រតិបត្តិការផ្តល់ឥណទានដល់អតិថិជន។ កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តគោលដៅ, តំណាងទីប្រឹក្សាអនុវត្តគម្រោង (PIC) និងមន្ត្រីឥណទានរបស់ស្ថាប័នហិរញ្ញវត្ថុដៃគូរួមមានធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ វគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីឥណទានថ្នាក់ស្រុក ខេត្ត លើប្រតិបត្តិការផ្តល់ឥណទាន ក្នុងក្របខណ្ឌគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១"។

## គោរពវិញ្ញាណក្ខន្ធសព ឯកឧត្ដម ជា ចាន់តូ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ដែលបានទទួលមរណភាព

នាព្រឹកថ្ងៃចន្ទ ១១រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែតុលា គ.ស.២០២៤ **ឯកឧត្ដម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងសហការី បានចូលរួមជាមួយគណៈប្រតិភូ នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដឹកនាំដោយ **ឯកឧត្ដម មី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្ដម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ដែលបានទទួលមរណភាពកាលពីថ្ងៃសុក្រ ៨រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៥ ខែតុលា គ.ស.២០២៤ វេលាម៉ោង ១០:៣៥ នាទីព្រឹក ក្នុងជន្មាយុ ៧៣ឆ្នាំ ដោយរោគាពាធ។




រូបភាព៖ "គោរពវិញ្ញាណក្ខន្ធសព ឯកឧត្ដម ជា ចាន់តូ តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា ដែលបានទទួលមរណភាព។

## វេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត"

នៅថ្ងៃពុធ ១៣រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែតុលា គ.ស.២០២៤ នៅសណ្ឋាគារ សុខា ភ្នំពេញ, និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំវេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា (**អ.ស.ហ.**) និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។




រូបភាព៖ វេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត"។

## កិច្ចពិភាក្សា និងបទបង្ហាញក្នុងវេទិកា "បរធនបាលកិច្ច ឆ្នាំ ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត"

កម្រងរូបភាពសកម្មភាពក្នុងវគ្គកិច្ចពិភាក្សា និងបទបង្ហាញក្នុងវេទិកា "បរធនបាលកិច្ច ឆ្នាំ២០២៤" ក្រោមប្រធានបទ "បរធនបាលកិច្ច៖ លើសពីថ្នាលបង្កើតទំនុកចិត្ត" ដែលមានការអញ្ជើញចូលរួមពីអ្នកជំនាញជាន់ខ្ពស់ក្នុងវិស័យបរធនបាលកិច្ចជាតិនិងអន្តរជាតិមកពីប្រទេសសិង្ហបុរី, ហុងកុង, ហ្វីលីពីន និងម៉ាឡេស៊ី។




រូបភាព៖ វេទិកាពិភាក្សា"កាលានុវត្តភាព និងគុណប្រយោជន៍នៃការប្រើប្រាស់យន្តការបរធនបាលកិច្ច"។




រូបភាព៖ វេទិកាពិភាក្សា“បរធនបាលកិច្ចគ្រួសារសម្រាប់ការរៀបចំផែនការតជំនាន់”។




រូបភាព៖ វេទិកាពិភាក្សា“បច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យបរធនបាលកិច្ច”។

## សិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ស្តីពីការវិភាគស្ថានភាព នៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២៣

នារសៀលថ្ងៃព្រហស្បតិ៍ ១៤រោច ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ខែតុលា គ.ស. ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ស្តីពីការវិភាគស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២៣ ក្រោមក្របខណ្ឌជំនួយបច្ចេកទេសរបស់ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ានបូក៣ (AMRO) ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយតំណាងធនាគារជាតិនៃកម្ពុជា តំណាងអគ្គនាយកដ្ឋានគោលនយោបាយ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងនិយ័តករក្រោមឱវាទ **អ.ស.ហ.**។




រូបភាព៖ សិក្ខាសាលាផ្សព្វផ្សាយស្តីពី របាយការណ៍ស្តីពីការវិភាគស្ថានភាពនៃវិស័យហិរញ្ញវត្ថុមិនមែនធនាគារ ឆ្នាំ២០២៣



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888